ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សេចក្តីប្រកាសព័ត៌មាន

ក្រសួងអប់រំ យុវជន និងកីឡា សូមជម្រាបជូនសាធារណជនជ្រាបថា នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ នាទីស្តីការក្រសួងអប់រំ យុវជន និងកីឡា មានពិធីចុះហត្ថលេខាបន្តអនុស្សរណៈនៃការយោគយល់ស្តីពី **"កម្មវិធីអ៊ីនធឺណិតតាមសាលារៀន"** រវាងក្រសួងអប់រំ យុវជន និងកីឡា តំណាងដោយ**ឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រី** និងលោក **Nguyen Thanh Nhuong អគ្គនាយក**ក្រុមហ៊ុនមិត្តហ្វូន។

តាមរយៈកិច្ចព្រមព្រៀងរយៈពេល ៥ឆ្នាំនេះ ក្រុមហ៊ុនមិត្តហ្វូននឹងផ្តល់សេវាកម្មអ៊ីនធឺណិតល្បឿនលឿនដោយមិនគិតកម្រៃសាលារៀនសាធារណៈ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ សាកលវិទ្យាល័យរដ្ឋ និងអង្គភាពរដ្ឋបាលអប់រំថ្នាក់ជាតិ និងក្រោមជាតិនៅទូទាំងប្រទេស ។

កម្មវិធីអ៊ីនធឺណិតតាមសាលារៀននឹងផ្តល់ឱកាសដល់ក្រសួងអប់រំ យុវជន និងកីឡាអាចមានលទ្ធភាពចែករំលែកធនធានបង្រៀន-រៀន និងផ្តល់ការសិក្សាតាមបណ្តាញអ៊ីនធឺណិតបានយ៉ាងទូលំទូលាយ ។ សិស្សានុសិស្ស និស្សិតនឹងមានជម្រើស និងមានភាពបត់បែនច្រើនជាងមុនសម្រាប់ឱកាសសិក្សារៀនសូត្រលើបណ្តាញ ដោយមិនគ្រាន់តែរង់ចាំការសិក្សារៀនសូត្រនៅតាមថ្នាក់ ក្នុងសាលារៀនទៀតទេ។

គំនិតផ្តួចផ្តើមថ្មីរបស់មិត្តហ្វូនត្រូវបានទទួលស្គាល់ជាក្រុមហ៊ុនទូរគមនាគមន៍ឈានមុខ ដែលបានបង្ហាញនូវចក្ខុវិស័យដ៏មុតមាំក្នុងការវិនិយោគលើវិស័យអប់រំ ដោយបាននាំយកនូវបច្ចេកវិទ្យាទំនើបបំផុតរបស់ពិភពលោកមកកម្ពុជា និងផ្តល់ឱកាសដ៏មហិមាដល់យុវជនកម្ពុជាជំនាន់ថ្មី ដែលនឹងក្លាយជាអ្នកដឹកនាំកម្ពុជានាពេលអនាគត សម្រេចបាននូវសក្តានុពលរបស់ខ្លួន។ កម្មវិធីនេះគឺជាជំហានចាប់ផ្តើមនៃការប្រើប្រាស់ចំណេះដឹង និងជំនាញបច្ចេកវិទ្យាព័ត៌មាន ដើម្បីត្រួសត្រាយផ្លូវឆ្ពោះទៅកាន់អនាគតដ៏ភ្លឺស្វាង។ សិស្ស និស្សិត លោកគ្រូ អ្នកគ្រូ និងបុគ្គលិកអប់រំជិត ១ លាននាក់នឹងទទួលបានអត្ថប្រយោជន៍ពីកម្មវិធីនេះ ។

បច្ចេកវិទ្យាអ៊ីនធឺណិតល្បឿនលឿននឹងដើរតួនាទីដ៏មានសក្តានុពលមួយផងដែរ សម្រាប់ការអភិវឌ្ឍជំនាញសមត្ថភាពសតវត្សទី២១ ។ កម្មវិធីនេះនឹងជួយព្រះរាជាណាចក្រកម្ពុជាឆ្ពោះទៅសម្រេចបានគោលដៅសង្គមប្រកបដោយពុទ្ធិ និងការអប់រំអេឡិចត្រូនិក ដែលនឹងរួមចំណែកកាត់បន្ថយគម្លាតឌីជីថលរបស់កម្ពុជាក្នុងតំបន់ និងលើពិភពលោក។

អាស្រ័យហេតុនេះ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦

អាសយដ្ឋានលេខ ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ : (៨៥៥-២៣) ៨៦៧ ៣២៦ / ២១៧ ២៥៣ ទូរសារ : (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh គេហទំព័រ: www.moeys.gov.kh